ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ..១៤..គ.សសរ

# សេចក្តីសំរេច
## ស្តីពី
## ការបង្កើតការិយាល័យសន្តិសុខថ្នាក់ខេត្ត-ក្រុង ប្រចាំនៅខេត្តស្ទឹងត្រែង

## ការិយាល័យសន្តិសុខថ្នាក់កណ្តាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៩០២ ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

-បានឃើញសេចក្តីសំរេចលេខ ៥៥សសរ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០០២ ស្តីពីការបង្កើតគណៈបញ្ជាការការពារការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រអាណត្តិទី ៣

-ផ្អែកតាមការចាំបាច់របស់ការិយាល័យសន្តិសុខថ្នាក់កណ្តាល

## សំរេច

**ប្រការ១** : ត្រូវបានបង្កើតការិយាល័យសន្តិសុខថ្នាក់ខេត្ត ប្រចាំនៅខេត្តស្ទឹងត្រែង ដែលមានសមាសភាពដូចតទៅ :

| | | | |
|---|---|---|---|
| ១-ឯកឧត្តម | ឈឹម ឈន | អភិបាលខេត្ត | ប្រធាន |
| ២-លោកឧត្តមសេនីយ៍ត្រី | នាម អឿន | មេបញ្ជាការរងយោធភូមិភាគទី ១ | អនុប្រធាន |
| ៣-ឯកឧត្តម | អោក មុនី | អភិបាលរងទី ១ ខេត្ត | អនុប្រធាន |
| ៤-លោកវរៈសេនីយ៍ឯក | ឡុង លឹម | ស្នងការនគរបាលខេត្ត | សមាជិក |
| ៥-លោកវរៈសេនីយ៍ឯក | ខាំ ស៊ុក | មេបញ្ជាការតំបន់ប្រតិបត្តិការសឹករងខេត្ត | សមាជិក |
| ៦-លោកវរៈសេនីយ៍ឯក | សឿន ម៉ុនរិទ្ធិ | មេបញ្ជាការកងរាជអាវុធហត្ថខេត្ត | សមាជិក |
| ៧-លោក | អួន បូរ៉ា | នាយខុទ្ទកាល័យសាលាខេត្ត | សមាជិក |
| ៨-លោកវរៈសេនីយ៍ទោ | ខួន គឿន | ស្នងការរងទី ១ នគរបាលខេត្ត | សមាជិក |
| ៩-លោក | ឡុង ផល | ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្ត | សមាជិក |
| ១០-លោក | ហ៊ីង ផាន់រឿន | ប្រធានមន្ទីរសាធារណការ និងដឹកជញ្ជូនខេត្ត | សមាជិក |
| ១១-លោក | ម៉ុក ទ៉ារី | ប្រធានមន្ទីរព័ត៌មានខេត្ត | សមាជិក |

**ប្រការ២** : ការិយាល័យសន្តិសុខថ្នាក់ខេត្តមានភារកិច្ច :

-ផ្សព្វផ្សាយ និងចាត់តាំងអនុវត្តផែនការលេខ ០១ផក ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០០៣ ស្តីពីផែនការការពារសន្តិសុខ សុវត្ថិភាពក្នុងដំណើរការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រអាណត្តិទី ៣ របស់ការិយាល័យសន្តិសុខថ្នាក់កណ្តាល ។

-រៀបចំបង្កើតការិយាល័យសន្តិសុខថ្នាក់ស្រុក ឃុំ តាមសេចក្តីសំរេចលេខ ០១សណរ ចុះថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០០៣ របស់ការិយាល័យសន្តិសុខថ្នាក់កណ្តាល ។

-ទទួលគោលការណ៍ ផែនការផ្សេងៗពីការិយាល័យសន្តិសុខថ្នាក់កណ្តាល និងផ្សព្វផ្សាយដល់ការិយាល័យសន្តិសុខថ្នាក់ស្រុក ឃុំ ព្រមទាំងណែនាំចាត់តាំងអនុវត្តឱ្យមានប្រសិទ្ធិភាព ។

-រៀបចំចាត់ចែង និងប្រើប្រាស់កម្លាំងគ្រប់ប្រភេទតាមផែនការកំណត់ និងណែនាំឱ្យកម្លាំងទាំងនោះអនុវត្តបានត្រឹមត្រូវ តាមបទបញ្ជា នីតិវិធីរបស់គ.ជ.ប និងច្បាប់បោះឆ្នោត ។

-ចាត់ចែងប្រើប្រាស់មធ្យោបាយ ឧបករណ៍សំភារៈរបស់បណ្តាអង្គភាពដែលមាន ស្រាប់ដើម្បីបំរើដល់កិច្ចការពារសន្តិសុខ សណ្តាប់ធ្នាប់សម្រាប់ការបោះឆ្នោត ។

-ប្រមូលផ្តុំព័ត៌មាន និងសភាពការណ៍ផ្សេងៗពីការិយាល័យសន្តិសុខថ្នាក់ក្រោម បូកសរុបរាយការណ៍ផ្ញើជូនមកការិយាល័យសន្តិសុខថ្នាក់កណ្តាលឱ្យបានទាន់ពេលវេលា ។

-ពិនិត្យដោះស្រាយពាក្យបណ្តឹង ឬឧបទ្ទវហេតុផ្សេងៗពាក់ព័ន្ធដល់សន្តិសុខនៃការបោះឆ្នោតដែលកើតឡើងក្នុងរង្វង់ភូមិសាស្ត្ររបស់ខ្លួន និងធ្វើរបាយការណ៍ជូនមកកាន់ការិយាល័យសន្តិសុខថ្នាក់កណ្តាលរៀងរាល់ ១៥ថ្ងៃម្តង ។ ករណីចាំបាច់ត្រូវរាយការណ៍ជាបន្ទាន់មកការិយាល័យសន្តិសុខថ្នាក់កណ្តាល ។

-ធ្វើគំរោងថវិកា ឧបករណ៍សំភារៈ មធ្យោបាយដឹកជញ្ជូនគ្រប់ប្រភេទបំរើការងារបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រសំរាប់មណ្ឌលស្ទឹងត្រែង ដាក់ជូនការិយាល័យសន្តិសុខថ្នាក់កណ្តាលពិនិត្យសំរេច ។

k

-ធ្វើរបាយការណ៍ចំណូលចំណាយថវិកា និងការប្រើប្រាស់ឧបករណ៍សំភារៈ មធ្យោបាយលើមូលដ្ឋាននៃគំរោងដែលការិយាល័យសន្តិសុខថ្នាក់កណ្តាលបានធ្វើការបែងចែកដល់ការិយាល័យសន្តិសុខគ្រប់ថ្នាក់ និងកងកម្លាំងទាំងអស់ ។

**ប្រការ ៣:** ការិយាល័យសន្តិសុខថ្នាក់ខេត្តមានសិទ្ធិប្រើប្រាស់ត្រារបស់សាលាខេត្តស្ទឹងត្រែង និងមានសិទ្ធិបង្កើតក្រុមជំនួយការអចិន្ត្រៃយ៍ដើម្បីជាជំនួយក្នុងការតាមដានគ្រប់សភាពការណ៍ និងជួយដឹកនាំបញ្ជាតាមការណែនាំរបស់ប្រធានការិយាល័យសន្តិសុខថ្នាក់ខេត្ត ។

**ប្រការ ៤:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ អគ្គស្នងការដ្ឋាននគរបាលជាតិ ប្រធានលេខាធិការដ្ឋាន ការិយាល័យសន្តិសុខថ្នាក់កណ្តាល មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស គណៈបញ្ជាការឯកភាពខេត្តស្ទឹងត្រែង និងសមាសភាពដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តសេចក្តីសំរេចនេះឱ្យមានប្រសិទ្ធិភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែកុម្ភៈ ឆ្នាំ ២០០៣

**ឧបនាយករដ្ឋមន្ត្រី**

**និងជាប្រធានការិយាល័យសន្តិសុខថ្នាក់កណ្តាល**

**ស ខេង**

កន្លែងទទួលៈ
- -ទីស្តីការគណៈរដ្ឋមន្ត្រី
- -ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- -ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី ស ខេង
- -គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- -លេខាធិការដ្ឋានការិយាល័យសន្តិសុខថ្នាក់កណ្តាល
- -ដូចប្រការ ៤
- -សាលាខេត្តស្ទឹងត្រែង
- -ឯកសារ-កាលប្បវត្តិ